# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# សកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋាន
# គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ប្រចាំឆ្នាំ ២០០៧

គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា(**គ.ទ.ក**) ត្រូវបានបង្កើតឡើងសំរាប់គ្រប់គ្រងដំណើរការនៃការធានានិងលើកកំពស់គុណភាពអប់រំឧត្តមសិក្សានៅកម្ពុជា ឱ្យមានប្រសិទ្ធិភាពខ្ពស់ស្របតាមស្តង់ដារអន្តរជាតិ ។ **គ.ទ.ក** មានអគ្គលេខាធិការដ្ឋានមួយជាអង្គភាពប្រតិបត្តិ ដែលមានតួនាទីយ៉ាងសំខាន់ក្នុងការបំពេញបេសកកម្មនិងអនុវត្តរាល់ភារកិច្ចទាំងឡាយរបស់គណៈកម្មាធិការនេះ។ នៅក្នុងឆ្នាំ ២០០៧កន្លងមក អគ្គលេខាធិការដ្ឋានបានបំពេញបេសកកម្មនិងអនុវត្តរាល់ភារកិច្ចរបស់ខ្លួនដូចខាងក្រោមៈ

## I- លទ្ធផលការងារ

### ១-ការងាររៀបចំស្តង់ដារនិងការទទួលស្គាល់គុណភាពអប់រំ

#### ក. ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន

១. ការងារពិនិត្យនិងយល់ព្រមលើការស្នើសុំកែប្រែកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋានរបស់ គ្រឹះស្ថានឧត្តមសិក្សា ដូចមានរាយនាម :

- សាកលវិទ្យាល័យ វេស្ទើន
- សាកលវិទ្យាល័យ ធនធានមនុស្ស
- សាកលវិទ្យាល័យ កម្ពុជា
- សាកលវិទ្យាល័យ បញ្ញាសាស្ត្រ
- សាកលវិទ្យាល័យ អន្តរជាតិ
- សាកលវិទ្យាល័យ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- សាកលវិទ្យាល័យ ជាតិគ្រប់គ្រង
- សាកលវិទ្យាល័យ មេគង្គ
- វិទ្យាស្ថាន វ៉ាន់ដា

២. ការងារពិនិត្យ និងផ្តល់ការយល់ព្រមលើកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន និងយល់ព្រមលើលក្ខខណ្ឌផ្សេងៗ ដល់គ្រឹះស្ថានឧត្តមសិក្សា :

- វិទ្យាស្ថាន សហព័ន្ធអឺរុប
- សាកលវិទ្យាល័យ សៅស៍អ៊ីសថ៍អេយសៀ

- ពុទ្ធិកសាកលវិទ្យាល័យ ព្រះសីហនុរាជ
- សាកលវិទ្យាល័យ អង្គរ
- សាកលវិទ្យាល័យ ឡាយហ្វ
- វិទ្យាស្ថាន អប់រំពាណិជ្ជសាស្ត្រ
- វិទ្យាស្ថាន វិទ្យាសាស្ត្រគ្រប់គ្រង
- វិទ្យាស្ថាន វ៉ាន់ដា

៣. ពិគ្រោះ និងផ្តល់យោបល់លើកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋានដល់សាលាភូមិន្ទនគរបាលកម្ពុជា និង សាលាសុខាភិបាលខេមរភូមិន្ទ

៤. បកប្រែជាភាសាអង់គ្លេសលើសៀវភៅណែនាំ ស្តីពីដំណើរការថ្នាក់ឆ្នាំសិក្សាមូលដ្ឋានសម្រាប់គ្រឹះស្ថានឧត្តមសិក្សា សៀវភៅណែនាំ ស្តីពីដំណើរការនៃការចុះវាយតម្លៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋានសំរាប់មន្ត្រីវាយតម្លៃឧត្តមសិក្សាបទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌សំរាប់មន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សា និង សេចក្តីព្រាងស្តង់ដាអប្បរមា និងឯកសារដទៃទៀត

៥. កែសម្រួលសៀវភៅណែនាំឆ្នាំសិក្សាមូលដ្ឋានសំរាប់គ្រឹះស្ថានឧត្តមសិក្សា និងសៀវភៅណែនាំសំរាប់មន្ត្រីវាយតម្លៃគុណភាពអប់រំថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៧

៦. ចុះវាយតម្លៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ២០០៥-២០០៦ លើកទី២ នៅសាកលវិទ្យាល័យ ស៊ីធី ថ្ងៃទី ១២ ដល់ ១៤ ខែមីនា ឆ្នាំ ២០០៧

៧. ចុះពិនិត្យ និងតាមដានលើការបណ្តុះបណ្តាលថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ឆ្នាំសិក្សា ២០០៥-២០០៦ និង ២០០៦-២០០៧ របស់វិទ្យាស្ថាន វិទ្យាសាស្ត្រគ្រប់គ្រងថ្ងៃទី ៣១ ខែ ឧសភា ដល់ ថ្ងៃទី០២ ខែ មិថុនា ឆ្នាំ ២០០៧

៨. ចុះពិនិត្យ និងតាមដានលើការបណ្តុះបណ្តាលថ្នាក់ឆ្នាំសិក្សាមូលដ្ឋានឆ្នាំសិក្សា២០០៥-២០០៦ និង ២០០៦-២០០៧ នៅ សាកលវិទ្យាល័យ វេនឡែន ថ្ងៃទី ០៦ ខែ ឧសភា ដល់ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០០៧

៩. ប្រជុំផ្សព្វផ្សាយសៀវភៅណែនាំ និងដាក់អោយអនុវត្តដំណើរការទទួលស្គាល់ដល់គ្រឹះស្ថានឧត្តមសិក្សា និងផ្សព្វផ្សាយសៀវភៅណែនាំរបស់មន្ត្រីវាយតម្លៃដល់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន

១០. ណែនាំសាលាភូមិន្ទនគរបាលជាតិ ដើម្បីរៀបចំកម្មវិធីសិក្សា ខែវិច្ឆិកា ឆ្នាំ ២០០៧

១១. ធ្វើបទបង្ហាញនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៧

១២. ធ្វើបទបង្ហាញនៅសកលវិទ្យាល័យអន្តរជាតិ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៧។

១៣. ការចុះវាយតម្លៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន

នៅឆ្នាំ២០០៧ គ.ទ.ក បានចាត់តាំងក្រុមមន្ត្រីវាយតម្លៃ ចុះវាយតម្លៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន នៅតាមគ្រឹះស្ថានឧត្តមសិក្សាទាំងនៅរាជធានីភ្នំពេញនិងខេត្ត-ក្រុងនានា ចំនួន ៦៦ គ្រឹះស្ថានឧត្តមសិក្សាដែលក្នុងនោះទទួលបានលទ្ធផលដូចខាងក្រោម:

- គ្រឹះស្ថានឧត្តមសិក្សាទទួលស្គាល់ពេញសិទ្ធិ ចំនួន ៣៣។ គ្រឹះស្ថាន សាធារណៈ ០៩ និង ឯកជន ២៤ ។
- គ្រឹះស្ថានឧត្តមសិក្សាទទួលស្គាល់បណ្តោះអាសន្នចំនួន ៣១។ គ្រឹះស្ថានសាធារណៈ ០៧ និងឯកជន ២៤។

- គ្រឹះស្ថានឧត្តមសិក្សាមិនទទួលស្គាល់ចំនួន០២ ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន ។

## ខ. ស្តង់ដារអប្បរមា

យោងតាមស្មារតីនៃព្រះរាជក្រឹត្យ លេខ ០៣០៣/១២៩/រកត ចុះថ្ងៃទី ៣១ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា **គ.ទ.ក** ត្រូវបង្កើតស្តង់ដារអប្បរមាមួយដែលមានលក្ខណៈវិនិច្ឆ័យ៩សំរាប់ជាមូលដ្ឋានក្នុងវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា ដើម្បីផ្តល់ការទទួលស្គាល់គុណភាពអប់រំគ្រឹះស្ថានឧត្តមសិក្សាទាំងមូល (Institutional Accreditation) ។

អនុវត្តតាមស្មារតីនេះ អគ្គលេខាធិការដ្ឋាន គ.ទ.ក បានចាប់ផ្តើមរៀបចំសេចក្តីព្រាងស្តង់ដារ អប្បរមារនេះ ដោយមានការឧបត្ថម្ភថវិកាពីធនាគារពិភពលោក។ សេចក្តីព្រាងនេះ បានដាក់ជូនអ្នកជំនាញការបរទេសផ្តល់យោបល់ចំនួនពីរលើក និងបានដាក់ឱ្យពិភាក្សាក្នុងអង្គសិក្ខាសាលាចំនួន៣លើក ដើម្បីប្រមូលយោបល់និងសំណូមពរពីគ្រឹះស្ថានឧត្តមសិក្សានានា និងក្រសួងពាក់ព័ន្ធ។

សេចក្តីព្រាងស្តង់ដារអប្បរមានេះ នឹងត្រូវបញ្ចប់រួចរាល់នៅដើមឆ្នាំ២០០៨ ខាងមុខ មុននឹងដាក់ជូន គ.ទ.ក ពិនិត្យ និងអនុម័ត ។

## គ.សិក្ខាសាលាក្នុងប្រទេស និង ការងារផ្សេងៗ

១. រៀបចំសិក្ខាសាលា ស្តីពី ការកែសម្រួលសៀវភៅណែនាំថ្នាក់ឆ្នាំសិក្សាមូលដ្ឋានសំរាប់គ្រឹះស្ថានឧត្តមសិក្សា ថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៧

២. រៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការរៀបចំស្តង់ដាអប្បបរមាសំរាប់ការទទួលស្គាល់គុណភាពអប់រំគ្រឹះស្ថានឧត្តមសិក្សា នៅទីក្រុងព្រះសីហនុ ថ្ងៃទី០៤ ដល់ ០៧ ខែកក្កដា ឆ្នាំ២០០៧

៣. រៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការរៀបចំស្តង់ដាអប្បបរមាសំរាប់ការទទួលស្គាល់គុណភាពអប់រំគ្រឹះស្ថានឧត្តមសិក្សានៅសណ្ឋាគារភ្នំពេញ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧

៤. រៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការរៀបចំស្តង់ដាអប្បបរមា សំរាប់ការទទួលស្គាល់គុណភាពអប់រំគ្រឹះស្ថានឧត្តមសិក្សានៅសណ្ឋាគារ HIMAWARI ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៧។

៥. រៀបចំបទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌សំរាប់មន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សា

## ២_ការងារកិច្ចសហប្រតិបត្តិការនិងព័តមាន

## ក-ការងារសហប្រតិបត្តិការ

១. លោក ប៉ែន ស៊ីថុល តំណាងអគ្គលេខាធិការដ្ឋាន គ.ទ.ក. ទៅចូលរួមសន្និសីទរបស់ APQN ស្តីពីទស្សនៈពិភពលោកនៃការធានាគុណភាពអប់រំឧត្តមសិក្សាដែលបានប្រព្រឹត្តទៅថ្ងៃទី ៤-៧ ខែ កុម្ភៈ ឆ្នាំ ២០០៧ នៅទីក្រុង Kuala Lumpur, Malaysia ។

២. លោក ប៉ែន ស៊ីថុល តំណាងអគ្គលេខាធិការដ្ឋាន គ.ទ.ក. បានទៅចូលរួមសន្និសីទរបស់ APQN ស្តីពីការធ្វើឱ្យប្រសើរឡើងនូវគុណភាពអប់រំឧត្តមសិក្សា ដែលបានប្រព្រឹត្តទៅថ្ងៃទី ១២-១៣ ខែ មីនា ឆ្នាំ ២០០៧ នៅទីក្រុង Ho Chi Minh City , Vietnam ។

៣. លោក ពៅ ពិសិដ្ឋ តំណាងអគ្គលេខាធិការដ្ឋាន គ.ទ.ក. ទៅចូលរួមក្នុងសន្និសីទប្រចាំឆ្នាំ ២០០៧ របស់ AERA ស្តីពី គុណភាពអប់រំពិភពលោក ដែលបានប្រព្រឹត្តទៅថ្ងៃទី ១១-១៣ ខែ មេសា ឆ្នាំ

២០០៧ នៅទីក្រុង Chicago , USA និង ទំនាក់ទំនងជាមួយ APQN ដើម្បីរៀបចំធ្វើជាម្ចាស់ផ្ទះក្នុងការប្រជុំប្រចាំឆ្នាំ២០០៩ នៅកម្ពុជា

៤. លោក ប៉ែន ស៊ីថុល តំណាងអគ្គលេខាធិការដ្ឋានគ.ទ.ក. ទៅចូលរួមសន្និសីទរបស់ APQN ស្តីពីការអភិវឌ្ឍន៍កម្រិតនៃការធានាគុណភាពអប់រំឧត្តមសិក្សា ដែលបានប្រព្រឹត្តទៅថ្ងៃទី៣០-៣១ ខែឧសភា ឆ្នាំ២០០៧ នៅទីក្រុង Dhaka, Bangladesh & ទំនាក់ទំនងជាមួយលោកស្រី Pijano ដើម្បីធ្វើសេចក្តីព្រាង MOU រវាង ACC និង PASSCU រៀបចំ Training Planសម្រាប់ World Bank ស្រាវជ្រាវរកប្រធានបទសម្រាប់ Training ឆ្នាំ ២០០៨ សំណើពី APQNសុំឱ្យ គ.ទ.ក. ដាក់ Logo APQN Member ក្នុង Website រៀបចំដាក់ពិន្ទុសម្រាប់ TA និង សហការទំនាក់ទំនងជាមួយលោកស្រី Lynn ( World Bank ) ពីការរៀបចំ Training Plan សម្រាប់ឆ្នាំ ២០០៧រហូតដល់ពាក់កណ្តាលឆ្នាំ២០០៨។

៥. ថ្នាក់ដឹកនាំ អគ្គលេខាធិការដ្ឋាន គ.ទ.ក. បីរូប គឺឯកឧត្តម បណ្ឌិតរដ្ឋ តិច សំណាង លោក ស៊ូ សុផាន និង លោក ប៉ែន ស៊ីថុល ក្នុងការស្វែងរកជំនួយ សម្រាប់ គ.ទ.ក. ដែលបានប្រព្រឹត្តទៅ ខែ ឧសភា ឆ្នាំ ២០០៧ នៅទីក្រុង Seoul , Korea ។

៦. ខែមិថុនា ឆ្នាំ២០០៧ ទទួលសំណើរបស់ APQN ដែលតំណាងឱ្យរដ្ឋាភិបាលប្រទេសអូស្ត្រាលីស្តីពីកម្មវិធីស្រង់មតិលើវិស័យអប់រំឧត្តមសិក្សានៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក តម្រូវឱ្យ ACC ចូលរួមឆ្លើយនូវសំណួរ ចំនួន៩១ សំណួរ ហើយផ្ញើត្រឡប់ទៅ APQN វិញឱ្យបានមុនថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៧ និង ទទួលសំណើពី APQN ស្នើឱ្យមន្ត្រី គ.ទ.ក.ដែលបានចូលរួមក្នុងកិច្ចប្រជុំរបស់ APQN ថ្ងៃទី៣០-៣១ខែឧសភាឆ្នាំ២០០៧ នៅទីក្រុង Dhaka, Bangladesh ចូលរួមឆ្លើយនូវសំណួរ Event Feedback Questionnaire និងរៀបចំបកប្រែអត្ថបទជាភាសា អង់គ្លេសដើម្បីថ្លែងអំណរគុណដល់លោក Dr Jae-Youl, Dr Byeong GiLee, Dr Soon-Young Hur, Mr Kim និង លោក Young Shik នៃប្រទេសកូរ៉េ។

៧. លោក សុខ ឃន លោកស្រី ស្រី ម៉ាលីនលោក ខៀវ វិជ្ជានន្ទ និង លោក ឡាយ សុបញ្ញា បានទៅចូលរួមសិក្ខាសាលា ថ្ងៃទី២៨-៣០ ខែវិច្ឆិកា ឆ្នាំ២០០៧ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន។

៨. ឯកឧត្តម បណ្ឌិតរដ្ឋ តិច សំណាង និង លោក ប៉ែន ស៊ីថុល ទៅចូលរួមសិក្ខាសាលាអន្តរជាតិ ស្តីពីសវនកម្មគុណភាពអប់រំនៅប្រទេសអូស្ត្រាលី នាថ្ងៃទី៣-៤ ខែធ្នូ ឆ្នាំ២០០៧

៩. ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ទ.ក. ពីររូប គឺ ឯកឧត្តម បណ្ឌិតរដ្ឋ តិច សំណាង និង លោកស្រី ស្រី ម៉ាលីន គណៈប្រតិភូ គ.ទ.ក. ទៅចូលរួមក្នុងសន្និសីទអន្តរជាតិលើកទី១ ប្រចាំឆ្នាំ ២០០៧ របស់ស្ថាប័ន ONLINE EDUCA MOSCOW ស្តីពី បច្ចេកវិជ្ជា និង ការបណ្តុះបណ្តាល ដើម្បីធានាគុណភាពអប់រំឧត្តមសិក្សា ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី ៣០ ខែកញ្ញា -ថ្ងៃទី០៣ ខែ តុលា ឆ្នាំ ២០០៧ នៅទីក្រុង MOSCOW , Russia ។

១០. លោក ស៊ូ សុផាន និង លោក ខៀវ វិជ្ជានន្ទ ទៅសិក្ខាសាលាស្តីពីយុទ្ធសាស្ត្រកំណែទម្រង់ឧត្តមសិក្សា ថ្ងៃទី០៣-០៥ ខែធ្នូ ឆ្នាំ២០០៧ នៅទីក្រុង កូឡាឡាំពួរ ប្រទេស ម៉ាឡេស៊ី។

១១. ខែវិច្ឆិកា ឆ្នាំ២០០៧ ទំនាក់ទំនងជាមួយប្រទេសឡាវ សម្រាប់លោក ស៊ូ សុផាន លោក ខៀវ វិជ្ជានន្ទនិង លោក ហ៊ាន ប៊ុនណិត ទៅចូលរួមក្នុងអង្គសិក្ខាសាលាស្ដីពីការធានាគុណភាព អប់រំឧត្តម សិក្សា នាថ្ងៃទី១១-១៣ ខែធ្នូ ឆ្នាំ២០០៧។ ប៉ុន្តែ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមិនបានសំរេចលើ គម្រោងថវិកាសំរាប់សន្និសិទ្ធនេះទាន់ពេលវេលា ដែលធ្វើឱ្យមន្ត្រី ២រូប គឺ លោក ស៊ូ សុផាន និង លោក ហ៊ាន ប៊ុនណិតមានការខកខានមិនបានចូលរួមក្នុងសន្និសីទនេះ។

១២. លោក ពៅ ពិសិដ្ឋ និង លោកហ៊ាន ប៊ុនណិត តំណាងអគ្គលេខាធិការដ្ឋាន គ.ទ.ក បានទៅចូលរួម ក្នុងសន្និសីទអន្តរជាតិ ស្ដីពី ការអភិវឌ្ឍន៍ឧត្តមសិក្សា របស់ AAIR ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី ២៨-៣០ ខែវិច្ឆិកា ឆ្នាំ ២០០៧ នៅទីក្រុង Sydney , Australia ។

១៣. បន្តកិច្ចទំនាក់ទំនងជាមួយអង្គការ និង ស្ថាប័នធានាគុណភាពអប់រំឧត្តមសិក្សាទាំងក្នុងតំបន់ និង អន្តរជាតិ ដូចជា : MoEYS, AUN, APQN, WORLD BANK, PCO, CESSP, UNESCO, JABEE, CHEA and AERA (USA), Malaysia, Vietnam, Russia, Philippine, Bangladesh, Thai, United Kingdom, New Zealand, USA , Japan, South Korea,Tanzania និង Paris ជាដើម។

**ការងារព័ត៌មាននិងស្រាវជ្រាវ**

១. តាមដានបន្តនូវការចុះផ្សាយព័ត៌មានជាតិ និង អន្តរជាតិ ដែលពាក់ព័ន្ធនឹងការងារគុណភាពអប់រំ

២. កែលំអទស្សនាវដ្ដី " គុណភាពអប់រំ " របស់ **គ.ទ.ក**

៣. កែលំអ គេហទំព័រ **គ.ទ.ក**

៤. រៀបចំបណ្ណាល័យ គ.ទ.ក សម្រាប់ការសិក្សាស្រាវជ្រាវពីគុណភាពអប់រំ

៥. កែលំអគោលនយោបាយ គ.ទ.ក បទដ្ឋានសហប្រតិបត្តិការ និង លិខិតបទដ្ឋានគតិយុត្តរបស់ គ.ទ.ក

៦. ស្រាវជ្រាវព័ត៌មានឬទិន្នន័យដែលពាក់ព័ន្ធនឹងគុណភាពអប់រំតាម Newspapers,Internet, Website

៨. ចូលរួមក្នុងដំណើរបេសកកម្ម នៃការចុះវាយតម្លៃគុណភាពអប់រំឆ្នាំសិក្សាមូលដ្ឋានតាមគ្រឹះស្ថានឧត្តម សិក្សា អង្គប្រជុំ សិក្ខាសាលា និង សន្និសីទនានាជាច្រើន ទាំងថ្នាក់ជាតិ និង អន្តរជាតិ ស្ដីពី គុណភាពអប់រំ

៩. ស្រាវជ្រាវកម្មវិធីជាតិនិងអន្តរជាតិ សម្រាប់ការងារគុណភាពអប់រំ

- រៀបចំគម្រោង Training Plan សម្រាប់ World Bank
- ស្រាវជ្រាវកម្មវិធីនៃការងារគុណភាពអប់រំតាម Internet
- ស្រាវជ្រាវកឯកសារដែលទាក់ទងនឹងវិស័យអប់រំឧត្តមសិក្សា
- ចុះពិនិត្យជាក់ស្ដែងនៅសាកលវិទ្យាល័យឡាហ្វនាក្រុងព្រះស៊ីហនុ និង សាកលវិទ្យាល័យបាត់ដំបង
- បានបញ្ជូនមន្ត្រីទៅបណ្ដុះបណ្ដាលបន្ថែម៥រូបខាងភាសាអង់គ្លេសនៅ ACE និង ៥រូបខាង IT នៅ IIC

# ៣.ការងារកិច្ចការទូទៅ

## ក.ផ្នែករដ្ឋបាល

- បានអញ្ជើញមន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សាចូលរួមប្រជុំពិភាក្សាប្ដូរយោបល់លើការ ចុះវាយតម្លៃលើដំណើរការថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននៅតាមគ្រឹះស្ថានឧត្តមសិក្សាឆ្នាំថ្មី ។

- បានបញ្ជូនលិខិតទៅគ្រឹះស្ថានឧត្តមសិក្សាដើម្បីធ្វើការណែនាំអោយចេញវិញ្ញាបនបត្រថ្នាក់ឆ្នាំសិក្សា មូលដ្ឋាន ២០០៥-២០០៦ ដល់និស្សិតដែលបានបញ្ចប់ការសិក្សាឆ្នាំទី១។
- បានអញ្ជើញឯកឧត្តម លោក លោកនាយកនៃគ្រឹះស្ថានឧត្តមសិក្សាចូលរួមប្រជុំ ស្តីពីបញ្ហាពាក់ព័ន្ធនឹងដំណើរការបណ្តុះបណ្តាលថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន និងការបង់វិភាគទានសេវារដ្ឋបាលជូនគ.ទ.ក។
- បានអញ្ជើញតំណាងគ្រឹះស្ថានឧត្តមសិក្សា និងក្រសួងពាក់ពន្ធ័ចូលរួមសិក្ខាសាលា នៅក្រុងព្រះសីហនុ ស្តីពី ការផ្តល់យោបល់លើសេចក្តីព្រាងស្តង់ដារអប្បបរមា សំរាប់ការទទួលស្គាល់គុណភាពអប់រំគ្រឹះស្ថានឧត្តមសិក្សា ។
- បានទទួលថវិកាបង់វិភាគទានសេវារដ្ឋបាលពីគ្រឹះស្ថានឧត្តមសិក្សា ចំនួន ៦៣ ។
- រៀបចំការចុះវាយតម្លៃលើដំណើរការបណ្តុះបណ្តាលថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ឆ្នាំសិក្សា ២០០៦-២០០៧ នៅគ្រឹះស្ថានឧត្តមសិក្សា ចំនួន ៦៦។
- រៀបចំការចុះពិនិត្យតាមដានលើដំណើរការវាយតម្លៃ ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ឆ្នាំសិក្សា ២០០៦-២០០៧ នៅគ្រឹះស្ថានឧត្តមសិក្សា ចំនួន ២៨ ។
- បានរៀបចំលិខិតរដ្ឋបាលមួយចំនួនផ្ញើទៅដល់គ្រឹះស្ថានឧត្តមសិក្សា និងស្ថាប័នពាក់ព័ន្ធ។
- បានទទួលសម្ភារៈការិយាល័យពីគំរោងទ្រទ្រង់វិស័យអប់រំកម្ពុជាប្រចាំត្រីមាស។
- បានធ្វើសំណើសុំថវិកាពីគំរោងទ្រទ្រង់វិស័យអប់រំកម្ពុជាសំរាប់ចុះវាយតម្លៃលើដំណើរការបណ្តុះបណ្តាលថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ឆ្នាំសិក្សា ២០០៦-២០០៧ នៅតាមបណ្តាខេត្ត ក្រុង។
- បញ្ជូនសេចក្តីជូនដំណឹងស្តីពីការជ្រើសរើសមន្ត្រីវាយតម្លៃគុណភាពអប់រំទៅតាមគ្រឹះស្ថានឧត្តមសិក្សា ។
- សំណើសុំទៅគំរោងទ្រទ្រង់វិស័យអប់រំកម្ពុជា នូវគ្រឿងអេឡិចត្រូនិច មួយចំនួន។
- បានបោះពុម្ពសៀវភៅសំរាប់មន្ត្រីវាយតម្លៃ និងសំរាប់គ្រឹះស្ថានឧត្តមសិក្សាព្រមទាំងក្បាលលិខិតសំរាប់អគ្គលេខាធិការដ្ឋាន ។
- បានទៅចូលរួមប្រជុំនៅកន្លែងគំរោងទ្រទ្រង់វិស័យអប់រំកម្ពុជាអំពីការបើកកញ្ចប់នៃការដេញថ្លៃនៃអ្នកផ្គត់ផ្គង់សំភារៈជូនអគ្គលេខាធិការដ្ឋាន ។
- បានរៀបចំសិក្ខាសាលា នៅសណ្ឋាគារឆ្នេរថ្មីក្រុងព្រះសីហនុស្តីពីការផ្តល់យោបល់លើសេចក្តីព្រាងស្តង់ដារអប្បបរមាសំរាប់ការទទួលស្គាល់គុណភាពអប់រំគ្រឹះស្ថានឧត្តមសិក្សាចាប់ពីថ្ងៃទី ៥-៧ ខែ កក្កដា ឆ្នាំ ២០០៧ ។
- បានរៀបចំសិក្ខាសាលា នៅសណ្ឋាគារភ្នំពេញ ស្តីពីការផ្តល់យោបល់លើសេចក្តីព្រាងស្តង់ដារអប្បបរមាសំរាប់ការទទួលស្គាល់គុណភាពអប់រំគ្រឹះស្ថានឧត្តមសិក្សាចាប់ពីថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ។
- បានរៀបចំសិក្ខាសាលា នៅសណ្ឋាគារ HIMAWARI ក្រុងភ្នំពេញ ស្តីពីការផ្តល់យោបល់លើសេចក្តីព្រាងស្តង់ដារអប្បបរមាសំរាប់ការទទួលស្គាល់គុណភាពអប់រំគ្រឹះស្ថានឧត្តមសិក្សាចាប់ពីថ្ងៃ ទី ២១ ខែ ធ្នូ ឆ្នាំ ២០០៧ ។
- បានទទួលពាក្យដាក់សុំបំរើការងារជាមន្ត្រីវាយតំលៃគុណភាពអប់រំថ្មី

## ខ-អំពីកិច្ចប្រជុំ គ.ទ.ក

នៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៧ នៅសាលប្រជុំទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា(គ.ទ.ក) បានបើកកិច្ចប្រជុំមួយក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ជាប្រធានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ។ អង្គប្រជុំបានពិភាក្សា លើរបៀបវារៈដូចខាងក្រោមៈ

១. របាយការណ៍សង្ខេបស្តីពីលទ្ធផល និង សកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋាន គ.ទ.ក

២. ការពិភាក្សា និង អនុម័តផ្តល់ការទទួលស្គាល់គុណភាពអប់រំថ្នាក់ឆ្នាំសិក្សាមូលដ្ឋានដល់គ្រឹះស្ថានឧត្តមសិក្សា

៣. បញ្ហាផ្សេងៗ

## គ-អំពីបុគ្គលិក

នៅឆ្នាំ ២០០៧ អគ្គលេខាធិការដ្ឋានមានមន្ត្រី ចំនួន ២៥ រូប និង មន្ត្រីជាប់កិច្ចសន្យាចំនួន ១៦រូប ។

## II- ទិសដៅការងារនាពេលខាងមុខ

-បញ្ចប់ស្តង់ដារអប្បរមារសំរាប់ផ្តល់ការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សាមុនដាក់ជូន គ.ទ.ក ពិនិត្យ និង សំរេច

-បង្កើតឧបករណ៍ស្វ័យវាយតំលៃសំរាប់ការទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សា

-រៀបចំសេចក្តីណែនាំសំរាប់គ្រឹះស្ថានឧត្តមសិក្សាពីររបៀបប្រើប្រាស់ឧបករណ៍ស្វ័យវាយតំលៃ

-រៀបចំសៀវភៅណែនាំមន្ត្រីវាយតំលៃសំរាប់ការចុះវាយតំលៃគ្រឹះស្ថានឧត្តមសិក្សា

- កំណត់នីតិវិធីក្នុងការផ្តល់ការទទួលស្គាល់គុណភាពអប់រំ ដល់គ្រឹះស្ថានឧត្តមសិក្សា

-រៀបចំសិក្ខាសាលាបណ្តុះបណ្តាលមន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សាដែលទើបបានជ្រើសរើសថ្មី

-រៀបចំសិក្ខាសាលាបណ្តុះបណ្តាលមន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សា អំពីស្តង់ដាអប្បបរមាសំរាប់ការទទួលស្គាល់គុណភាពអប់រំសំរាប់គ្រឹះស្ថានឧត្តមសិក្សាទាំងមូល

-បញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីជំនាញចុះណែនាំពិនិត្យ និងអង្កេតនៅតាមគ្រឹះស្ថានឧត្តមសិក្សា

-រៀបចំចងក្រងសៀវភៅណែនាំទូទៅសំរាប់បណ្តុះបណ្តាលមន្ត្រីវាយតម្លៃ

-ចុះធ្វើការណែនាំពីការរៀបចំកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋានរបស់គ.ទ.ក និងតាមដាន អង្កេតគ្រឹះស្ថានឧត្តមសិក្សាមួយចំនួនដែលមានទីតាំងក្នុងក្រុងភ្នំពេញនិងតាមបណ្តាខេត្ត

-ជ្រើសរើសមន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សាសំរាប់អាណត្តិទី២

-ធ្វើការផ្សព្វផ្សាយបង្កើនការយល់ដឹង អំពីស្តង់ដាអប្បរមាសំរាប់គ្រឹះស្ថានឧត្តមសិក្សាតាមរយៈសិក្ខាសាលាបណ្តុះបណ្តាលផ្សេងៗ

-ចុះធ្វើបទបង្ហាញពីសៀវភៅណែនាំសំរាប់ការទទួលស្គាល់គុណភាពអប់រំនៅតាមបណ្តាគ្រឹះស្ថានឧត្តមសិក្សាទូទាំងប្រទេស

-ចុះពិនិត្យតាមដាន និងអង្កេតដំណើរការបណ្តុះបណ្តាលថ្នាក់ឆ្នាំសិក្សាមូលដ្ឋានតាមគ្រឹះស្ថានឧត្តមសិក្សាដែលទទួលការទទួលស្គាល់គុណភាពអប់រំពេញសិទ្ធ ចំនួន ៣៣

-ចុះវាយតម្លៃលើដំណើការបណ្តុះបណ្តាលថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន នៅតាមគ្រឹះស្ថានឧត្តមសិក្សាដែល

ទទួលស្គាល់បណ្តោះអាសន្ន ចំនួន៣១

-ចុះធ្វើបទបង្ហាញដើម្បីបង្កើនការយល់ដឹង និងការអនុវត្តកម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីត និងការផ្ទេរក្រេឌីតតាមគ្រឹះស្ថានឧត្តមសិក្សា

-វិភាគទិន្នន័យលើលទ្ធផលនៃការវាយតម្លៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ២០០៦-២០០៧

-ធ្វើការសិក្សាពីផលប្រយោជន៍ពីការវាយតម្លៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ២០០៤-២០០៧

-រៀបចំបង្កើតលក្ខខណ្ឌចុះឈ្មោះចូលរៀនសំរាប់និស្សិតពុំបានឆ្លងកាត់កម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន

-រៀបចំវេទិការសាធារណៈស្តីពីការធានាគុណភាពអប់រំ និងការទទួលស្គាល់គុណភាពអប់រំ

-រៀបចំប្រមូល និងសិក្សាស្រាវជ្រាវបទដ្ឋានអន្តរជាតិនានាសំរាប់ការបង្កើតក៏រិតគុណវុឌ្ឍិសិក្សា (Qualification Framwork) ពីក៏រិតបរិញ្ញាបត្រដល់ក៏រិតបណ្ឌិត ។

-បន្តកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីសុំចូលជាសមាជិក របស់ INQAAHE និងស្វែងរកជំនួយបច្ចេកទេស និងហិរញ្ញវត្ថុផ្សេងទៀត

-ស្នើសុំអ្នកជំនាញការបរទេសដើម្បីជួយរៀបចំបទដ្ឋានបច្ចេកទេសនានា

- កំណត់គោលការណ៏សំរាប់ផ្តល់ការយល់ព្រមដល់គ្រឹះស្ថានឧត្តមសិក្សា ក្នុងការកំណត់លក្ខ័ខណ្ឌសំរាប់និស្សិតវ័យចំណាស់ និងនិស្សិតមកពីគ្រឹះស្ថានមធ្យមសិក្សាបច្ចេកទេស ឬ គ្រឹះស្ថានសិក្សាក្រោយមធ្យមសិក្សាទុតិយភូមិ

-បញ្ជូនមន្ត្រីទៅធ្វើការសិក្សាស្វែងយល់ និងដកស្រង់បទពិសោធន៍ពាក់ព័ន្ធនឹងការធានាគុណភាពអប់រំ ពីប្រទេសនានា ក្រោមជំនួយរបស់ធនាគាពិភពលោក និងជំនួយផ្សេងទៀត

-បន្តកិច្ចសហប្រតិបត្តិការនេះបន្តទៀត ជាមួយប្រទេស និង អង្គការអន្តរជាតិនានា ដើម្បីស្វែងរកជំនួយបច្ចេកទេស និង ហិរញ្ញវត្ថុ ។

- បន្តកិច្ចសហប្រតិបត្តិការ ជាមួយ ក្រសួង-ស្ថាប័នពាក់ព័ន្ធ នានា

- ធ្វើសំណើសុំប្រេងឥន្ធនៈសំរាប់ឆ្នាំ២០០៨ ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- ធ្វើសំណើថវិការជូនទេយ្យសំរាប់ឆ្នាំ ២០០៨ ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- ជ្រើសរើសបុគ្គលិកដែលមានសញ្ញាប័ត្រខ្ពស់មួយចំនួនបន្ថែមទៀត

- បន្តអនុវត្តភារកិច្ចចាំបាច់មួយចំនួនទៀតរបស់អគ្គលេខាធិការដ្ឋាន គ.ទ.ក ។

## III- **សេចក្តីសន្និដ្ឋាន**

ដោយសារតែមានការគាំទ្រយ៉ាងខ្លាំងពីរាជរដ្ឋាភិបាល និងពីសំណាក់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ព្រមទាំងការខិតខំប្រែងរបស់ថ្នាក់ដឹកនាំនិងមន្ត្រីទាំងអស់របស់ អគ្គលេខាធិការដ្ឋាន ក្នុងឆ្នាំ២០០៧កន្លងមក អគ្គលេខាធិការដ្ឋានបានបំពេញភារកិច្ចទៅតាមផែនការការងាររបស់ខ្លួនប្រកបដោយជោគជ័យ និងទទួលលទ្ធផលល្អ ទាំងការងារផ្ទៃក្នុង និងការងារកិច្ចសហប្រតិបត្តិការជាតិ និង អន្តរជាតិ ។